# មេរៀនទី ២២៖ ទេវតាបានជួយរំដោះពេត្រុសពីគុក

[កិច្ចការ ១២៖១-១៨]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/AvypoXMHlHk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/YJnqQ3ohbjo

**គោលបំណង៖** ព្រះអង្គបានចាត់ទេវតាមកដើម្បីជួយយើង

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៩១៖១១** *"ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ពីដំណើរឯងឲ្យបានថែរក្សាឯងក្នុងគ្រប់ទាំងផ្លូវរបស់ឯង"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo
២. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE
៣. ខ្ញុំអាចធ្វើគ្រប់ការអ្វីបានទាំងអស់ https://youtu.be/RAti7KCmIvM

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **« បំបែកប៉េងប៉ោង »**



សម្ភារៈដែលត្រូវការ៖

ខ្សែសំរាប់ចងប៉េងប៉ោង,ខ្សែ( សម្រាប់ចងកជើងកុមារ )

១. ឲ្យកុមារចាប់ដៃគូ២នាក់ៗជាក្រុម

២. គ្រូយកខ្សែចងកជើងកុមារពីរនាក់ជាប់គ្នា និងចងប៉េងប៉ោងនៅជើងពួកគេដែលទំនេរ។

៣.កុមារទាំងអស់ត្រូវប្រើប្រអប់ជើងរបស់ពួកគេក្នុងការបំបែកប៉េងប៉ោងរបស់ក្រុមផ្សេងទៀត ប៉ុន្តែនៅក្នុងពេលជាមួយគ្នានោះដែរពួកគេត្រូវព្យាយាមការពារប៉េងប៉ោងក្រុមរបស់ខ្លួនមិនត្រូវឲ្យគេបំបែកបានផងដែរ។

៤.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងមិនអាចធ្វើកិច្ចការនេះតែម្នាក់ឯងបាននោះទេ យើងអាចធ្វើវាបានដោយសារមានការជួយពីអ្នកដទៃ ហើយនៅក្នុងពេលជាមួយគ្នានោះដែរ ព្រះយេស៊ូវបានបញ្ជូនទេវតាមកជួយដល់យើង។

**៤. ការណែនាំមេរៀន** **«តើព្រះគម្ពីរនិយាយអ្វីខ្លះអំពីទេវតា ?»**

សម្ភារៈដែលត្រូវការ៖ បោះពុម្ពខគម្ពីរមួយចំនួន ហើយកាត់ចេញពីគ្នា ( សូមមើលនូវទំព័រខាងក្រោម )



ប្អូនៗតើធ្លាប់ឃើញអ្នកជាប់គុកទេ ? ចុះប្អូនៗធ្លាប់ឃើញទេវតាទេ ? តើទេវតាជាអ្វី ?

១.ចែកកុមារជាក្រុម ដោយក្នុងមួយក្រុមមានគ្នាពី ៣ ទៅ ៤ នាក់រួចឲ្យ ខគម្ពីរ ១ ឬ ២ ទៅកាន់ក្រុមនីមួយៗ។

២.ឲ្យក្រុមនីមួយៗអាននូវខគម្ពីរ របស់ពួកគេ រួចឲ្យពួកគេនិយាយ ពន្យល់ថាតើព្រះគម្ពីរបាននិយាយអ្វីខ្លះពីទេវតា។
៣.បន្ទាប់ពីអានខគម្ពីររួចហើយ កុមារទាំងអស់គួរតែដឹងថាទេវតាបាន ជួយនិងការពារដល់មនុស្ស ឬក៏បញ្ជូនសាររបស់ព្រះមកកាន់យើង។ ដោយសារតែសេក្តីស្រលាញ់របស់ទ្រង់ព្រះអង្គបានបញ្ជូនទេវតារបស់ទ្រង់ដើម្បីជួយដល់យើង។ សូមឲ្យយើងបានក្រឡេកទៅមើលពីសាច់រឿង ដែលព្រះបានបញ្ជូលទេវតារបស់ទ្រង់មកជួយដល់ពេត្រុស។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជាយូរលង់ណាស់មកហើយ ជាពេលដែលស្តេចហេរ៉ូដបានចាប់សាវករបស់ព្រះយេស៊ូវម្នាក់ដាក់គុក។ សាវកនោះមានឈ្មោះថា ពេត្រុស។ នៅពេលដែលមិត្តភក្តិរបស់ពេត្រុសដឹងថាគាត់ជាប់ក្នុងគុក ពួកគេទាំងនោះបារម្ភជាខ្លាំង។ មិត្តភក្តិរបស់ពេត្រុសបានអធិស្ឋានឲ្យគាត់ និងសុំឲ្យព្រះជាម្ចាស់ជួយការពារគាត់ឲ្យបានសុខ។ ព្រះអង្គបានឮពីសេចក្តីអធិស្ឋាននោះ។ ទ្រង់បានចាត់ជំនួយការដ៏ពិសេសម្នាក់ ដើម្បីទៅរំដោះពេត្រុសចេញពីគុក។ ជំនួយការដ៏ពិសេសម្នាក់នោះគឺជាទេវតានៃព្រះ! យើងមិនបានដឹងថាទេវតានោះមានឈ្មោះអ្វីនោះទេ ប៉ុន្តែដឹងត្រឹមតែថាទេវតានោះបានលេចឡើងនៅពេលដែលពេត្រុសកំពុងគេងលក់។ នៅពេលនោះមានពន្លឺភ្លឺឡើងនៅក្នុងគុក។ ទេវតាបានដាស់ពេត្រុសឲ្យភ្ញាក់ឡើង ហើយច្រវាក់ក៏ជ្រុះពីដៃគាត់ចេញ! ទេវតានោះបានប្រាប់ឲ្យពេត្រុសក្រោកឡើង ហើយស្លៀកពាក់ទៅ។ បន្ទាប់មកទេវតាបាននាំពេត្រុសចេញពីគុក ដោយឆ្លងកាត់អ្នកយាមជាច្រើននាក់ រហូតទៅដល់ផ្ទះរបស់មិត្តភក្តិគាត់ដោយសុវត្ថិភាព! វាហាក់ដូចជាគ្មានអ្នកណាម្នាក់ដឹងថាពេត្រុសបានដើរចេញពីគុកនោះឡើយ ហើយសូម្បីតែពេត្រុសខ្លួនឯងក៏គិតថាគាត់កំពុងយល់សប្តិដែរ រហូតទាល់តែគាត់បានដើរចេញមកដល់ផ្លូវខាងក្រៅ។ នេះគឺជាការអស្ចារ្យមួយ! ព្រះអង្គបានឆ្លើយតបទៅនឹងការអធិស្ឋានដែលមិត្តភក្តិរបស់ពេត្រុសបានអធិស្ឋានឲ្យគាត់ ដោយទ្រង់បានចាត់ទេវតារបស់ទ្រង់ទៅជួយរំដោះពេត្រុស!

ព្រះជាម្ចាស់បានចាត់ទេវតារបស់ទ្រង់មកជួយយើង ទោះបីជាសព្វថ្ងៃនេះក៏ដោយ! ព្រះអង្គទ្រង់ជ្រាបនូវអ្វីដែលយើងត្រូវការជំនួយ ហើយទេវតារបស់ទ្រង់នឹងនៅទីនោះជាមួយយើងដើម្បីធ្វើនូវកិច្ចការដែលព្រះបានបង្គាប់ពួកគេ។ មានពេលជាច្រើនដែលពួកយើងមិនបានដឹងថាពួកទេវតាទាំងនោះបានជួយយើង។ យើងមិនអាចមើលឃើញពួកគេបានទេ លើកលែងតែព្រះចង់ឲ្យយើងមើលឃើញពួកគេប៉ុណ្ណោះ។ នេះគឺដោយសារតែមានមនុស្សជាច្រើននឹងថ្វាយបង្គំទេវតា ជំនួសឲ្យការដែលពួកគេត្រូវថ្វាយបង្គំដល់ព្រះជាម្ចាស់។ ពួកទេវតានឹងទៅតែកន្លែងណាដែលព្រះចាត់ឲ្យពួកគេទៅតែប៉ុណ្ណោះ ហើយពួកគេក៏ធ្វើតែកិច្ចការណាដែលទ្រង់បានបង្គាប់ដល់ពួកគេផងដែរ។ ព្រះអង្គបង្គាប់ដល់ពួកទេវតាទាំងនោះឲ្យមកជួយពួកយើង! នេះគឺដោយព្រោះតែព្រះអង្គទ្រង់ស្រឡាញ់យើងជាខ្លាំង!

សូមប្អូនគិតពីរឿងអ្វីមួយនៅក្នុងជីវិតរបស់ប្អូន ដែលប្អូនត្រូវការជំនួយមកពីព្រះជាម្ចាស់សម្រាប់ការនោះ។ ប្អូនប្រហែលជាត្រូវការជំនួយដូចជា ប្អូនចង់រៀនឲ្យបានពូកែ, ចង់ស្តាប់បង្គាប់ឪពុកម្តាយ ឬក៏ចង់ស្តាប់-បង្គាប់ព្រះជាម្ចាស់ឲ្យបានស្មោះត្រង់ជារៀងរាល់ថ្ងៃ។ ប្រហែលជាអ្នកត្រូវធ្វើអ្វីដែលពិបាកក្នុងសប្តាហ៍នេះ ឬ មនុស្សដែលប្អូនស្រឡាញ់ត្រូវការជំនួយពីព្រះ។ ប្អូនមួយចំនួនប្រហែលជាត្រូវការ ជំនួយពីទេវតាក្នុងសប្តាហ៍នេះ។ បើប្អូនត្រូវការ នោះព្រះនឹងចាត់ពួកទេវតាឲ្យមក ព្រោះព្រះជាម្ចាស់ជាអ្នកដែលចាត់ទេវតា។

មិនថាទ្រង់ចាត់ទេវតាមកឬអត់នោះទេ ក៏ព្រះអង្គនឹងមើលថែ ហើយទ្រង់ជ្រាបពីតម្រូវការរបស់ ប្អូនដែរ។ ព្រះអង្គល្អ!

## ៦. សំនួរពិភាក្សា

១. តើស្តេចហេរ៉ូដបានចាប់ខ្លួននរណា? *(ពេត្រុស)*

២. តើមិត្តភក្តិរបស់ពេត្រុសបានធ្វើអ្វីនៅពេលដែលពួកគេដឹងថាពេត្រុសត្រូវបានចាប់ខ្លួន? *(ពួកគេអធិស្ឋាន)*

៣. តើអ្នកណាជាអ្នកមករំដោះពេត្រុសចេញពីគុក? *(ទេវតា)*

៤. តើអ្នកណាជាអ្នកចាត់ទេវតាឲ្យមក? *(ព្រះ)*

៥. ថ្ងៃនេះប្អូនជឿថាព្រះអាចចាត់ទេវតាមកជួយប្អូននៅពេលប្អូនមានបញ្ហាទេ? (បាទ ឬចាស/ទេ) តើពេលនេះប្អូនត្រូវការឲ្យព្រះជួយអ្វីដល់ប្អូន? (ឲ្យកុមារឆ្លើយ)

## ៧. ល្បែងកំសាន្ត "ពិត" ឬ "មិនពិត"

១. សិស្សទាំងអស់ត្រូវឈរនៅកណ្តាលថ្នាក់រៀន

២. បើសិនជាគ្រូនិយាយពីអ្វីជាការពិតទាក់ទងនឹងទេវតា សិស្សត្រូវដើរទៅផ្នែកខាងក្រោយនៃបន្ទប់រៀន

៣. បើសិនជាគ្រូនិយាយអ្វីដែលជារឿងមិនពិតទាក់ទងនឹងទេវតា សិស្សត្រូវដើរមកខាងមុខនៃបន្ទប់រៀន

៤. បើសិនជាសិស្សមិនដឹងថាគ្រូនិយាយពិត ឬ មិនពិត សិស្សត្រូវឈរនៅកណ្តាលថ្នាក់រៀន

- ទេវតាគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ *(ពិត)*
- ទេវតាពិតជាខ្លាំងពូកែ *(ពិត)*
- ទេវតាពិតជាខ្លាំងពូកែដូចជាព្រះដែរ *(មិនពិត-ពួកគេធ្វើតាមតែអ្វីដែលព្រះបង្គាប់តែប៉ុណ្ណោះ)*
- ទេវតាចង់ឲ្យមនុស្សថ្វាយបង្គំពួកគេ *(មិនពិត-ពួកទេវតាក៏ថ្វាយបង្គំដល់ព្រះជាម្ចាស់ដែរ)*
- មនុស្សអាចធ្វើខ្លួនដូចជាទេវតាបាន *(មិនពិត-មនុស្សមិនអាចដូចជាទេវតាបានទេ)*
- ទេវតាមានស្លាបនិងរង្វង់ពន្លឺនៅពីលើ *(ព្រះគម្ពីរមិនបាននិយាយពីចំនុចនេះទេ)*
- ទេវតាគឺជាអ្នកនាំសារនៃព្រះ *(ពិត)*
- ទេវតាអាចធ្វើអ្វីដែលពួកគចង់ធ្វើបានគ្រប់យ៉ាង *(មិនពិត-ពួកគេធ្វើតែអ្វីដែលព្រះបានបង្គាប់ពួកគេតែប៉ុណ្ណោះ)*
- ទេវតាជាអ្នកការពារ និង ជួយសង្គ្រោះពួកយើង *(ពិត)*

៥. សូមចាំថា ព្រះបានចាត់ទេវតាមកពីព្រោះទ្រង់ស្រឡាញ់យើង។ យើងប្រហែលជាមិនដែលឃើញទេវតាក្នុងជីវិតរបស់យើងទេ ប៉ុន្តែយើងអាចប្រាកដថាពួកគេនៅជុំវិញយើង ដើរជាមួយយើង និងមើលថែយើង។ ទោះបីពួកគេធ្វើការអស្ចារ្យក៏ដោយ យើងមិនដែលថ្វាយបង្គំទេវតាឡើយ។ ពួកគេគ្រាន់តែបានបង្កើតមកដូចជាយើងដែរតែប៉ុណ្ណោះ។ មានតែព្រះមួយអង្គតែប៉ុណ្ណោះដែលយើងត្រូវថ្វាយបង្គំ និងសរសើរ ហើយទ្រង់គឺជាព្រះអទិករដែលបង្កើតយើងទាំងអស់គ្នាមក។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ៩១៖១១** *"ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ពីដំណើរឯងឲ្យ បានថែរក្សាឯងក្នុងគ្រប់ទាំងផ្លូវរបស់ឯង"។*

## ៩. ហាត្ថកម្ម «ព្រះជាម្ចាស់បានចាត់ទេវតាឲ្យមកជួយពួកយើង»

សម្ភារៈដែលត្រូវការ៖ បោះពុម្ពរូបភាពគម្រូទេវតាសម្រាប់សិស្សម្នាក់ៗ (សូមមើលរូបគម្រូនៅខាងក្រោម)



១. អាចតុបតែងរូបភាពគម្រូទេវតាដូចជាផាត់ពណ៌ជាដើម រួចកាត់ទៅតាមបន្ទាត់ដែលមានគម្រូស្រាប់

២. សូមបត់ទៅតាមគម្រូបន្ទាត់ដាច់ៗ ហើយបិទចំនុច A និង B ភ្ជាប់គ្នា (សូមមើលគម្រូរាងទេវតា ដែលបានធ្វើរួច)



៣. សូមរំឭកកុមារថាព្រះអង្គចាត់ទេវតាឲ្យមកជួយពួកគេ!

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
អ្នកកំពុងតែមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់តែងតែជ្រាបគ្រប់កិច្ចការទាំងអស់ ព្រមទាំងអ្វីដែលយើងមិនអាចយកឈ្នះបានផងដែរ។ ព្រះអង្គធ្វើចលនា និងធ្វើការអស្ចារ្យចំពោះអ្នកណា ដែលបានអធិស្ឋានទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ក្នុងនាមជាគ្រីស្ទបរិស័ទតើអ្នកអាចប្រើកម្លាំងដ៏ល្អបំផុតដែលអ្នកមាននៅក្នុងព្រះគ្រីស្ទយេស៊ូវដោយរបៀបណា?

# តើព្រះគម្ពីរនិយាយអ្វីខ្លះអំពីទេវតា?

| | |
|---|---|
| **ពង្សាវតាក្សត្រ ទី១ ១៩:៥-៨**<br>៥ លោកក៏ប្រះខ្លួនដេកលក់ នៅក្រោមដើមដង្កោ នោះទៅនោះមានទេវតាមកដាស់លោកប្រាប់ថាចូរក្រោកឡើងបរិភោគសិន ៦លោកក្រឡេកមើល ទៅឃើញនៅក្បាលដំណេកមាននំដុតឆ្អិនទៅលើ ថ្មុងភ្លើង ហើយមានទឹក១ ក្អមផង នោះលោកក៏បរិភោគនំនិងទឹកនោះ រួចដេកទៅវិញ ៧ទេវតានៃព្រះយេហូវ៉ាក៏មកដាស់ម្តងទៀតប្រាប់ថា ចូរក្រោកឡើងបរិភោគទៅ ដ្បិតផ្លូវដែលត្រូវដើរនោះហួសកំឡាំងឯងណាស់ ៨ លោកក៏ក្រោកឡើងបរិភោគទៅ ហើយ ដោយសារកំឡាំងដែលបានពីអាហារនោះ លោកក៏ដើរទៅ អស់៤០ថ្ងៃ៤០យប់ បានដល់ទៅភ្នំហោរែប ជាភ្នំនៃព្រះ។ | **ដានីយ៉ែល ១០:៥-៦,១៤**<br>៥នោះខ្ញុំបានងើបភ្នែកមើលទៅ ឃើញមានមនុស្ស ម្នាក់ស្លៀកពាក់ដោយសំពត់ទេសឯក ហើយក្រវាត់ចង្កេះដោយមាសសុទ្ធពីស្រុកអ៊ូផាស ៦រូបកាយរបស់អ្នកនោះ មើលទៅដូចជាត្បូងបេរីល ហើយមុខមានភាពដូចជាផ្លេកបន្ទោរ ឯភ្នែកក៏ដូចជាចន្លុះ ដៃលឆេះដៃនឹងជើងដូចជាលង្ហិនខាត់យ៉ាងភ្លឺ ហើយសូរសំឡេងរបស់អ្នកនោះដូចជាសូរនៃជំនុំមនុស្សយ៉ាងធំ … ១៤ ឥឡូវនេះបានមក ដើម្បីឲ្យអ្នកយល់ពីការដែល ត្រូវកើតដល់សាសន៍អ្នក នៅគ្រាក្រោយបង្អស់ ដ្បិតការជាក់ស្តែងនេះ សំដៅដល់យូរថ្ងៃទៅខាងមុខ។ |
| **អេសាយ ៦៣:៨-៩**<br>៨ដ្បិតទ្រង់បានមានព្រះបន្ទូលថា គេជារាស្ត្រអញពិត គឺជាកូនចៅដែលមិនព្រមប្រព្រឹត្តដោយវៀច កាញ់ឡើយ ដូច្នេះបានជាទ្រង់បានធ្វើជាព្រះអង្គសង្គ្រោះដល់គេ ៩ ក្នុងគ្រប់ទាំងសេចក្តីទុក្ខវេទនារបស់គេ នោះទ្រង់ក៏រងទុក្ខដែរ ហើយទេវតាដែល នៅចំពោះទ្រង់បានសង្គ្រោះគេ ទ្រង់បានប្រោសលោះគេ ដោយសេចក្តីស្រឡាញ់ និងសេចក្តីមេត្តា ករុណារបស់ទ្រង់ កាលពីចាស់បុរាណ ទ្រង់បាន លើកគេបីទៅជាដរាប។ | **ម៉ាថាយ ១:២០,២៤**<br>២០កាលដែលគាត់កំពុងតែគិតពីការនោះ ស្រាប់តែមានទេវតានៃព្រះអម្ចាស់ លេចមកពន្យល់សប្តិ ប្រាប់គាត់ថា យ៉ូសែបពូជហ្លួងដាវីឌអើយ កុំឲ្យ ខ្លាចនឹងយកនាងម៉ារា ជាប្រពន្ធអ្នកឡើយ ដ្បិត បុត្រដែលមកចាប់ទំផ្ទៃនាង នោះកើតពីព្រះវិញ្ញាណបរិសុទ្ធទេ….២៤ លុះយ៉ូសែបភ្ញាក់ពីដេក ឡើងនោះគាត់ក៏ធ្វើតាមបង្គាប់របស់ទេវតា នៃព្រះអម្ចាស់គឺគាត់យកប្រពន្ធមកនៅជាមួយ |
| **ម៉ាថាយ ៤:៦**<br>៦បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរទំលាក់ខ្លួន ទៅក្រោមចុះ ដ្បិតមានសេចក្តីចែងទុកមកថា«ទ្រង់នឹងបង្គាប់ពួកទេវតានៃទ្រង់ពីដំណើរអ្នក ទេវតានឹងទ្រអ្នកដោយដៃ ក្រែងលោជើងអ្នកទង្គិច នឹងថ្ម» | **ម៉ាថាយ ២:១៣**<br>១៣កាលគេចេញទៅបាត់ហើយ នោះទេវតានៃព្រះអម្ចាស់ក៏លេចមក ពន្យល់សប្តិប្រាប់យ៉ូសែបថា ចូរក្រោកឡើងនាំបុត្រតូច និងមាតាទ្រង់រត់ទៅឯស្រុកអេស៊ីព្ទ ទៅឲ្យនៅស្រុកនោះទាល់តែយើងប្រាប់ដ្បិតហេរ៉ូឌនឹងរកសំឡាប់ បុត្រ តូច |
| **ទំនុកដំកើង ៣៤:៧**<br>៧ទេវតានៃព្រះយេហូវ៉ាចោមរោមនៅជុំវិញនៃអស់ អ្នកដែលកោតខ្លាចដល់ទ្រង់ ហើយក៏ជួយគេឲ្យរួច | **លូកា ២២:៤៣**<br>៤៣នោះមានទេវតាលេចមកឯទ្រង់អំពីស្ថានសួគ៌ មកចំរើនកំឡាំងថ្វាយ។ |
| **យ៉ូហាន ២០:១២**<br>១២ ឃើញទេវតា២រូប ស្លៀកពាក់ស អង្គុយ១ខាង ក្បាល១ចុងជើង ត្រង់កន្លែងដែលបានផ្តេក ព្រះសពព្រះយេស៊ូវ។ | **ហេព្រើរ ១:៤**<br>៤ហើយដែលទ្រង់បានទទួលនាម១ទុកជាមរដក ជានាមដែលប្រសើរជាងនាមរបស់ពួកទេវតាប៉ុណ្ណា នោះទ្រង់ក៏បានត្រឡប់ជាវិសេសជាងពួកទេវតាប៉ុណ្ណោះដែរ។ |
| **កិច្ចការ ៨:២៦**<br>២៦ នោះទេវតានៃព្រះអម្ចាស់ មានព្រះបន្ទូលទៅភីលីពថា ចូរក្រោកឡើងទៅឯខាងត្បូងតាមផ្លូវ ដែលចុះពីក្រុងយេរូសា-ឡិម ទៅឯក្រុងកាសា ដែលជាទីរហោស្ថានទៅ។ | **វិវរណៈ ២២:៨-៩**<br>៨ គឺយ៉ូហានខ្ញុំ ដែលបានឃើញ ហើយឮសេចក្តី ទាំងនេះ លុះខ្ញុំឮ ហើយឃើញ នោះខ្ញុំក៏ទំលាក់ ខ្លួនរៀបនឹងថ្វាយបង្គំនៅទៀបជើងនៃទេវតា ដែលបង្ហាញឲ្យខ្ញុំឃើញសេចក្តីទាំងនេះ ៩ តែទេវតាប្រាប់ ខ្ញុំថា កុំឲ្យធ្វើដូច្នេះឡើយ ខ្ញុំក៏ជាបាវបំរើជាមួយនឹងអ្នកដែរ ហើយជាមួយនឹងពួកហោរា ជាបងប្អូនអ្នក និងពួកអ្នកដែលកាន់តាមព្រះបន្ទូលក្នុងគម្ពីរនេះផង ចូរថ្វាយបង្គំដល់ព្រះវិញចុះ។ |


A
B
A
B